ην προς τον θεον και θεος ην ο



# ជំពូក ១០
# ពិធីបុណ្យរំលង និង
# សេចក្ដីវេទនារបស់ព្រះគ្រីស្ទ


ទៅរៀបចំបុណ្យរំលង ព្រមទាំងអាហារសម្រាប់ យើងបរិភោគ ។
ខ្ញុំចង់ទទួលទាននៅថ្ងៃបុណ្យរំលងនេះជាមួយអ្នក មុនខ្ញុំទទួលរងទុក្ខវេទនា ។ ខ្ញុំនឹងមិនបានទទួលទានបុណ្យនេះទៀតទេ រហូតដល់នគរនៃព្រះបានមកដល់ផែនដីនេះ ហើយនៅថ្ងៃនោះអ្នកនឹង បរិភោគរួមគ្នានៅតុរបស់ខ្ញុំ ហើយអ្នកនឹងអង្គុយនៅលើបល្ល័ង្កដើម្បី ជំនុំជំរះពួកកុលសម្ព័ន្ធទាំង១២នៃសាសន៍អ៊ីស្រាអែល ។
ខ្ញុំនឹងប្រាប់អ្នករឿងមួយ ដូច្នេះនៅពេលរឿងនោះ កើតឡើងអ្នកនឹងជឿ គម្ពីរទំនុកតម្កើង ៤១:៩ បានទាយថា "**អ្នកដែលទូលបង្គំបានទុកចិត្ត ហើយក៏បានហូបនំបុ័ងរបស់ទូលបង្គំ នោះបានលើកកែងជើងចង់ជាន់ឈ្លីទូលបង្គំដែរ**" ខ្ញុំប្រាប់អ្នកថា មានម្នាក់ក្នុងចំណោមពួកអ្នក ដែលដាក់ដៃនៅ លើតុជាមួយខ្ញុំ អ្នកនោះនឹងក្បត់ខ្ញុំ ។
ទេ !
តាមសេចក្ដីសម្រេចមក ប៉ុន្តែ **វេទនា**ដល់មនុស្សម្នាក់ដែលនឹង ប្រព្រឹត្តដូច្នេះ ។
ព្រះជាម្ចាស់ ទូលបង្គំឬ ? ទូលបង្គំមិនចង់ក្បត់ទ្រង់ទេ ។
ព្រះអង្គ មិនមែន ទូលបង្គំទេឬ ?
លោកគ្រូ ខ្ញុំមិន ក្បត់លោកគ្រូទេ ។




ម៉ាថាយ ២៦:២៣-២៥, យ៉ូហាន ១៣:២៦-៣០




ម៉ាថាយ ២៦:៣៣-៣៥, យ៉ូហាន ១៣:៣១-៣៨, កូរិនថូសទី១, ១១:២៤-២៥




យ៉ូហាន ១៤:១-៣, កូរិនថូសទី១, ១១:២៤-២៦




ម៉ាថាយ ២៦:៣០, យ៉ូហាន ១៤:៥-១០, ១៥, ២៥-៣០




ម៉ាថាយ ២៦:៣១, ៣៨, យ៉ូហាន ១៦:១៩-២០, ១៧:១-១០




ទំនុកដំកើង ២៣:៥-៦, លូកា ២២:៤១-៤៤, ហេព្រើរ ៦:៦, ១២:២




ម៉ាថាយ ២៦:៤០, ៤៥-៥០, យ៉ូហាន ១២:២៧, ១៨:១-៤


យេស៊ូវ នៃក្រុង
ណាសារ៉ែត
គឺខ្ញុំនេះហើយ
សូមប្រយ័ត្ន ! វាមាន
អំណាចយ៉ាងខ្លាំង !
ទាហានទាំងនោះភ័យ
ខ្លាចព្រះយេស៊ូវ ហើយ
ក៏ដួលផ្ងារក្រោយ ។
នោះគឺវា
តើពួកឯងកំពុងខ្លាចអ្វី ?
ចាប់វាទៅ !
ពួកឯងមិនត្រូវចាប់
លោកគ្រូរបស់អញទេ !
ស្ទាប់ !
អ៊ូយយ៉ា...!




ម៉ាថាយ ២៦:៥២-៥៧, ម៉ាកុស ១៤:៥១-៥២, លូកា ២២:៥០-៥១


ទៅឱ្យលឿនឡើង ពួកគេចង់ឱ្យរឿងនេះចប់មុនពេល ប្រជារាស្ត្របានដឹងឮ ។
គេបាននាំព្រះយេស៊ូវ ទៅកន្លែងដែលពួកសង្ឃ និង សាក្សីទាំងអស់កំពុងជំនុំគ្នា ។
ពួកគេបានប្រាប់អញថា ឯងបាន តាំងខ្លួនជាព្រះមែស៊ី ហើយក៏និយាយពី ព្រះជាម្ចាស់ជាព្រះវរបិតារបស់ឯងដែរ ។ ឯងធ្លាប់និយាយទៀតថា ឯងមិនបានមកពី លោកិយទេ តើឯងមកពីទីណាវិញ ?
តើហេតុអ្វីបានជាលោកសួរខ្ញុំ ? ខ្ញុំបានបង្រៀននៅសាលាប្រជុំនិងក្នុងវិហារ ដែរ ខ្ញុំមិនបានបង្រៀនដោយសម្ងាត់ទេ សូមសួរពួកគេដែលធ្លាប់ស្ដាប់ខ្ញុំ ពួកគេដឹង នូវអ្វីដែលខ្ញុំបាននិយាយ ។
ផាំង...
ឯងមិនអាចឆ្លើយ នឹងសម្ដេចសង្ឃនូវ របៀបនេះទេ ។
បើសិនខ្ញុំបាននិយាយខុស ចូរបង្ហាញពីកំហុសនោះចុះ តែបើខ្ញុំនិយាយត្រូវ តើហេតុអ្វី លោកវាយខ្ញុំ ?
សូមនាំសាក្សីមកបង្ហាញ ពីកំហុសអាម្នាក់នេះ ។


វាបាននិយាយថា វាអាចកំទេចព្រះវិហារនិងសង់ឡើងវិញបានក្នុងរយៈពេល **៣ថ្ងៃ**ដោយមិនបាច់ប្រើដៃរបស់វា។
អត់ទេ ! វាបាននិយាយថាបើសិនអ្នកផ្សេងកំទេច នោះវានឹងសង់ឡើងវិញ។
ឯងមិនបាននៅទីនោះផង ខ្ញុំបានឮនូវអ្វីដែលវានិយាយ វាបានចង្អុលខ្លួនឯង នៅពេលវាកំពុងនិយាយអំពីការបំផ្លាញវិហារ ខ្ញុំគិតថាវាបាននិយាយពីការបំផ្លាញរូបកាយរបស់វា។
នោះគួរឱ្យអស់សំណើច តើវាសាងសង់រូបកាយវិញក្នុងរយៈពេល៣ថ្ងៃយ៉ាងម៉េច ?
ខ្ញុំមិនដឹងទេ ប៉ុន្តែតើវាអាចនឹងសាងសង់ព្រះវិហារក្នុងរយៈពេល៣ថ្ងៃយ៉ាងដូម្តេចដែរ ?
តើឯងបានឮគេកំពុងតែចោទប្រកាន់ឯងឬទេ ? តើឯង**ជំទាស់នឹង**គេទេ ?
ព្រះយេស៊ូវនៅតែស្ងៀម
**អាល្ងង់នេះ វាមិនព្រមឆ្លើយ**
អញបញ្ជាឯងឱ្យស្បថដល់ព្រះដ៏មានព្រះជន្មរស់ ចូរឯងឆ្លើយ តើឯងជា**ព្រះគ្រីស្ទ** ជាព្រះបុត្រានៃព្រះដ៏មានព្រះជន្មរស់ឬអត់ ?
**ខ្ញុំជា**រាជបុត្រានៃព្រះមែន ហើយអ្នកនឹងឃើញខ្ញុំគង់នៅខាងស្តាំនៃព្រះដ៏មានព្រះចេស្តា ហើយនឹងយាងត្រឡប់មកផែនដីនេះវិញនៅក្នុងពពក។
យើងមិនត្រូវការសាក្សីទៀតទេ យើងឮវានិយាយផ្ទាល់**ត្រចៀកយើង**ហើយ វាបានប្រមាថដោយអះអាងថា **វាជាបុត្រារបស់ព្រះ**។ វាត្រូវតែ**ងាប់ !**
យកកន្សែងចងភ្នែកវា យើងចង់ដឹងថា វាជាហោរាដូចម្តេច។
សម្តេចសង្ឃបានគិតថា បន្ទូលរបស់ព្រះយេស៊ូវជាការប្រមាថ ដូច្នេះគាត់ហែកអាវខ្លួនឯងដោយបង្ហាញថា គាត់កំពុងមានសេចក្តីវិនាសអន្តរាយយ៉ាងខ្លាំង។

ម៉ាថាយ ២៦:៥៩-៦៥




ម៉ាថាយ ២៦:៦៧-៧០, លូកា ២២:៦៤-៦៥




ម៉ាថាយ ២៦:៧១-៧៥, ២៧:១-២, លូកា ២២:៥៨-៦២, ២៣:១


យកខ្សែតីកន្ទុយ៩វាយវាទៅ !
ព្រះជាម្ចាស់អើយ ! ហេតុអ្វីបានជាទូលបង្គំធ្វើដូច្នេះ ? ទូលបង្គំបានបដិសេធ**បីដង** ដូចទ្រង់មានបន្ទូល ហេតុអ្វីមានការនេះកើតឡើង ? តើហេតុអ្វីទ្រង់ត្រូវ**រងការឈឺចាប់**ដូច្នេះ ?
មកឱ្យលឿន ពួកអញគ្មានពេលធ្វើការនេះពេញមួយយប់ទេ។
ព្រះវរបិតា សូមប្រទាន**កំលាំង**
ពេលយូដាសដឹងថា គេនឹងសម្លាប់ព្រះយេស៊ូវ គាត់យកប្រាក់សងពួកសង្ឃរាជវិញ។
ឯងមកទីនេះចង់បានអ្វី ? តើយើងឱ្យលុយមិនគ្រប់គ្រាន់ចំពោះការក្បត់គ្រូរបស់ឯងឬ ?
ខ្ញុំប្តូរគំនិតហើយ ចូរ**ដោះលែង**ទ្រង់វិញចុះ ខ្ញុំនឹង**សងលុយអ្នក**វិញ។
នេះគឺជា**លុយកខ្វក់ដែលប្តូរជីវិត** យើងមិនប៉ះទេ គ្រូរបស់ឯងនឹងស្លាប់មុនថ្ងៃនេះកន្លងផុតទៅ ឯងគ្មានអ្វីត្រូវខ្លាចទេ ប្រហែលយើងអាចប្រើឯងឱ្យជួយចាប់សិស្សរបស់វាទៀត។
**យក**លុយឯងវិញទៅ អញលែងត្រូវការហើយ អញមិនអាច**រស់នៅ**ដោយមាន**កំហុស**បែបនេះទេ។
ង៉ឹង !
គ្លីង !
គួរឱ្យអាណិត វាឆោតល្ងង់មែន។
ខ្ញុំមិនចង់**រស់**ទៀតទេ


ព្រះជាម្ចាស់អើយ ! ចិត្តរបស់ទូលបង្គំមិនស្ងប់សោះ តើហេតុអ្វីចេះតែខ្វល់ខ្វាយដូច្នេះ ។
ហេតុអ្វីខ្ញុំមិនអាចគ្រប់គ្រងចិត្តលោភលន់របស់ខ្ញុំបាន ។
ប្រហែលមានតែសេចក្តីស្លាប់ទេ ធ្វើឱ្យចិត្តខ្ញុំស្ងប់បាន ។
ខ្ញុំបានឃើញគាត់ ប៉ុន្តែខ្ញុំ**ឃាត់មិនទាន់** ។
យើងត្រូវ**ប្រញាប់ឡើង** និងកាត់ក្រមាទម្លាក់មក ប្រហែលគាត់**នៅរស់** !
ទោះបីជាពួកគេកំពុងតែឡើងទៅជួយគាត់ក៏ដោយ ក៏ព្រលឹងរបស់យូដាសកំពុងតែធ្លាក់ទៅកន្លែងមានភ្លើងដែលរងទុក្ខវេទនា ។
ពេលខ្ញុំកាត់ អ្នកទ្រវាឱ្យជាប់ ប្រយ័ត្នធ្លាក់ចូលជ្រោះ ។




សាការី ១១:១២-១៣, ម៉ាថាយ ២៧:៨, ម៉ាកុស ១៥:១៤, លូកា ២៣:១-៤, យ៉ូហាន ១៨:២៩-៣៨, កិច្ចការ ១:១៨







លូកា ២៣:១១, យ៉ូហាន ១៩:១-២


មើល៎ ខ្នងវាស្នាម ឡើងសុះ !
បាទ ព្រោះអីខ្ញុំចង់វាយ ស្តេចយូរហើយ ។
វាថា វាជាស្តេច ចូរពាក់រ៉ូប ពណ៌ស្វាយនេះលើវាទៅ ។
ស្តេចត្រូវការម្កុដដែរ
ហាស់ហាំ ! នេះ នឹងធ្វើជាម្កុដដ៏ល្អមួយ
អ៊ូយ ! មុត
យកដំបងរាជ្យនេះ ទៅ អូ ស្តេចដ៏ល្បីអើយ ។ ហាស់ ហាស់ !
ពាក់លើក្បាលវាឱ្យជាប់ រឹតឱ្យបានតឹង !
យើងអភិសេកឱ្យឯង ជាស្តេចលើពិភពលោក ទាំងមូល !
អ្ហ៎ា...!
ឥឡូវក្រោកឈរ ឱ្យត្រង់ ។
កាន់ដំបងរាជ្យឡើង ព្រះអង្គ ។
ហាស់ហាំ... សូមឱ្យ មានព្រះជន្មយឺនយូរ ។
មែន បើវាមានសំណាង វាអាចរស់រហូតដល់ថ្ងៃលិច ។




ទំនុកដំកើង ២២, អេសាយ ៥០:៦, ៥៣:៥, ៧, លូកា ២៣:១៣-២២, យ៉ូហាន ១៩:៤-៨

(**សេសារ** គឺជារបស្សនាម ស្តេច នៅជំនាន់អាណាចក្ររ៉ូម)




ម៉ាថាយ ២៧:២៤, យ៉ូហាន ១៩:៩-១៧




ម៉ាថាយ ២៧:៣២, លូកា ២៣:២៦-៣៣




ទំនុកដំកើង ២២, អេសាយ ៥២, ម៉ាថាយ ២៧:៣៣-៣៤




សាការី ១៣:៦, លូកា ២៣:៣២-៣៤




ទំនុកដំកើង ២២:១៨, ម៉ាថាយ ២៧:៣៩-៤៣, យ៉ូហាន ១៩:២៣-២៤




ទំនុកដំកើង ៦៩:២១, លូកា ២៣:៣៦-៤៣, យ៉ូហាន ១៩:២៥-២៧




ម៉ាថាយ ២៧:៤៥-៥០, លូកា ២៣:៤៤-៤៦, យ៉ូហាន ១៩:៣០, កូរិនថូសទី២, ៥:២១




ទំនុកដំកើង ៣៤:២០, សាការី ១២:១០, ម៉ាថាយ ២៧:៥៤, យ៉ូហាន ១៩:៣១-៣៧


យ៉ាងហោចណាស់
ក៏គេមិនវាយបំបាក់
ជើងទ្រង់ដែរ ។
អុំម៉ារា ខ្ញុំនឹងទៅរក
មនុស្សខ្លះដើម្បីនឹងជួយ
រៀបចំបញ្ចុះសពទ្រង់ ។
ថ្ងៃឈប់សម្រាកនឹងចាប់ផ្ដើមនៅពេលថ្ងៃលិច
ឥឡូវនេះវារសៀលហើយ ពួកគេត្រូវការធ្វើ
យ៉ាងប្រញាប់ ដើម្បីបញ្ចុះសពទ្រង់ទាន់ពេល ។
យ៉ូសែប ជាអ្នកមាន គាត់មិនមែន
ជាសិស្សម្នាក់ក្នុងចំណោម១២នាក់ទេ
គាត់បានសម្រេចចិត្តឱ្យផ្នូរថ្មីផ្ទាល់ខ្លួន
ដើម្បីបញ្ចុះសពព្រះយេស៊ូវ ។
ថ្ងៃឈប់សម្រាកនឹងមកដល់
ឆាប់ៗ យើងប្រញាប់យកសព
ទ្រង់បញ្ចុះនៅក្នុងផ្នូររបស់ខ្ញុំ ។
នេះជាការប្រពៃណាស់
យ៉ូសែប អ្នកគឺជាមិត្តដ៏ល្អ ។